## How are war criminals prosecuted under humanitarian law?

On becoming party to the Geneva Conventions, States undertake to enact any legislation necessary to punish persons guilty of grave breaches of the Conventions. States are also bound to prosecute in their own courts any person suspected of having committed a grave breach of the Conventions, or to hand that person over for judgment to another State. In other words, perpetrators of grave breaches, i.e. war criminals, must be prosecuted at all times and in all places, and States are responsible for ensuring that this is done. Generally speaking, a State's criminal laws apply only to crimes committed on its territory or by its own nationals. International humanitarian law goes further in that it requires States to seek out and punish any person who has committed a grave breach, irrespective of his nationality or the place where the offence was committed. This principle of universal jurisdiction is essential to guarantee that grave breaches are effectively repressed. Such prosecutions may be brought either by the national courts of the different States or by an international authority. In this connection, the International Criminal Tribunals for the former Yugoslavia and Rwanda were set up by the UN Security Council in 1993 and 1994, respectively, to try those accused of war crimes committed during the conflicts in those countries.

(ICRC, International Humanitarian Law, Answers to Your Questions, 2002)

## តើឧក្រិដ្ឋជនសង្គ្រាមត្រូវបានកាត់ទោសដោយរបៀបណា ក្រោមច្បាប់មនុស្សធម៌ ?

នៅពេលក្លាយជាភាគីនៃអនុសញ្ញាទីក្រុងហ្សឺណែវ (Geneva Conventions) រដ្ឋទាំងឡាយមានកាតព្វកិច្ច ធ្វើច្បាប់ណាមួយដែលចាំបាច់ដើម្បីផ្តន្ទាទោសជនដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរនៃអនុសញ្ញាទាំងនោះ។ រដ្ឋក៏មានកាតព្វកិច្ចកាត់ទោសនៅក្នុងតុលាការរបស់ខ្លួននូវជនណាមួយ ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរនៃអនុសញ្ញា ឬប្រគល់ជននោះទៅឱ្យរដ្ឋមួយផ្សេងទៀតដើម្បីវិនិច្ឆ័យ។ និយាយម្យ៉ាងទៀត ជនប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដូចជាឧក្រិដ្ឋជនសង្គ្រាម ត្រូវតែត្រូវបានកាត់ទោសនៅគ្រប់ពេលវេលានិងគ្រប់ទីកន្លែង ហើយរដ្ឋទាំងឡាយមានទំនួលខុសត្រូវក្នុងការធានាថាការនេះត្រូវបានធ្វើឡើង។ ជាទូទៅ ច្បាប់ព្រហ្មទណ្ឌរបស់រដ្ឋមួយអនុវត្តចំពោះតែឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងទឹកដីរបស់ខ្លួន ឬដោយប្រជាពលរដ្ឋរបស់ខ្លួនប៉ុណ្ណោះ។ ច្បាប់មនុស្សធម៌អន្តរជាតិបានឈានទៅមុខបន្ថែមទៀត ដោយតម្រូវឱ្យរដ្ឋទាំងឡាយស្វែងរកនិងផ្តន្ទាទោសជនណាម្នាក់ ដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដោយមិនគិតពីសញ្ជាតិរបស់ពួកគេ ឬទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្តនោះទេ។ គោលការណ៍នៃយុត្តាធិការជាសកល (universal jurisdiction) នេះគឺមានសារៈសំខាន់ណាស់ ដើម្បីធានាថាបទល្មើសធ្ងន់ធ្ងរត្រូវបានបង្ក្រាបដោយប្រសិទ្ធភាព។ ការកាត់ទោសបែបនេះ អាចត្រូវបានធ្វើឡើងដោយតុលាការជាតិនៃរដ្ឋផ្សេងៗគ្នា ឬដោយអាជ្ញាធរអន្តរជាតិ។ ទាក់ទងនឹងបញ្ហានេះ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរវ៉ាន់ដា (International Criminal Tribunals for the former Yugoslavia and Rwanda)

ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩៣ និងឆ្នាំ ១៩៩៤ ដើម្បីកាត់ទោសជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋសង្គ្រាម ដែលបានប្រព្រឹត្តក្នុងអំឡុងពេលជម្លោះនៅក្នុងប្រទេសទាំងនោះ។